# VII. ការប្រើវចនានុក្រមរូបភាព(utilisation du dictionnaire d’images)

វចនានុក្រម នឹងប្រើទាំងពីរទិស ៖ ពីឆ្វេងទៅស្តាំ (សម្រាប់រកបំប្លែងឡាប្លាស) និង ពីស្តាំទៅឆ្វេង ដើម្បីរកអនុគមន៍ដើម ។ ឧទាហរណ៍ខាងក្រោមនេះ នឹងបញ្ជាក់អំពីការរក អនុគមន៍ដើម (l’original)។

ឧទាហរណ៍-1

ចូររក បំប្លែងឡាប្លាស នៃអនុគមន៍ t -> ((*sin(3t)cos(2t)*)*U(t)*

ដោយប្រើរូបមន្តត្រីកោណមាត្រ ដែលយើងធ្លាប់ស្គាល់[1] គឺ ប្តូរ ពី គុណ មក បូក គេបាន៖

$f(t) = \frac{1}{2}[\sin(5t) + \sin(t)]U(t) = \frac{1}{2}.\sin(5t)U(t) + \frac{1}{2}.\sin(t)U(t)$

ដោយប្រើ លីនេអារីតេ នៃបំប្លែងឡាប្លាស និង វចនានុក្រមរូបភាព គេបាន៖

$$F(p) = \frac{1}{2}\left[\frac{5}{p^2+5^2}\right] + \frac{1}{2}\left[\frac{1}{p^2+1}\right]$$

រឺ

$$F(p) = \frac{1}{2}\left[\frac{5}{p^2+25}\right] + \frac{1}{2}\left[\frac{1}{p^2+25}\right] \qquad (1)$$

[1] $\sin(a).\cos(b) = \frac{1}{2}[\sin(a+b) + \sin(a-b)]$